Alameda County
Social Services
Agency

***ព័ត៌មាននេះគឺព័ត៌មានបច្ចុប្បន្ន និងត្រឹមត្រូវ គិតត្រឹមថ្ងៃទី11 ខែសីហាឆ្នាំ 2021។***

1. តើអ្វីទៅជាជនដែលស្ថិតក្រោមបន្ទុកសាធារណៈ**?**
ជនដែលស្ថិតក្រោមបន្ទុកសាធារណៈគឺជាពាក្យដែលប្រើនៅក្នុងច្បាប់អន្តោប្រវេសន៍ដើម្បីពិពណ៌នាអំពីបុគ្គលដែលអាចនឹងពឹងផ្អែកលើអត្ថប្រយោជន៍រដ្ឋាភិបាលដើម្បីទទួលបានការឧបត្ថម្ភផ្សេងៗ។

វិធាន "ជនក្រោមបន្ទុកសាធារណៈ" គឺជាការធ្វើតេស្តដែលប្រើប្រាស់ដោយផ្នែកសេវាសញ្ជាតិ និងអន្តោប្រវេសន៍អាមេរិក (USCIS) ដើម្បីសម្រេចថាតើនរណាខ្លះដែលខ្លួននឹងអនុញ្ញាតឱ្យចូលទៅក្នុងទឹកដីសហរដ្ឋអាមេរិក តើនរណាខ្លះដែលអាចបន្តទិដ្ឋាការបណ្តោះអាសន្នជាក់លាក់ និងតើនរណាខ្លះដែលអាចទទួលបានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ស្របច្បាប់ (LPR) ដែលហៅថា green card (ប័ណ្ណបៃតង)។ **សម្គាល់៖ វិធានស្តីពីជនក្រោមបន្ទុកសាធារណៈ <u>មិន</u> អនុវត្តចំពោះការស្នើសុំ** LPR **ដើម្បីទទួលបានសញ្ជាតិអាមេរិកឡើយ។**

2. **តើរដ្ឋាភិបាលសហព័ន្ធប្រើតេស្តជនក្រោមបន្ទុកសាធារណៈនៅពេលណា?**
វិធានស្តីពីជនក្រោមបន្ទុកសាធារណៈអនុវត្តចំពោះស្ថានភាពអន្តោប្រវេសន៍ស្របច្បាប់មួយចំនួនតូច សូមមើលសំណួរលេខ 10 និងត្រឹមតែចំណុចជាក់លាក់នៅលើផ្លូវអន្តោប្រវេសន៍ប៉ុណ្ណោះ (immigration pathway)។

ជាទូទៅ តេស្តជនក្រោមបន្ទុកសាធារណៈត្រូវបានអនុវត្តនៅពេលមានបុគ្គលណាម្នាក់៖
- ដាក់ពាក្យស្នើសុំសិទ្ធិចូលទឹកដីសហរដ្ឋអាមេរិក
- ដាក់ពាក្យស្នើសុំកែសម្រួលស្ថានភាពអន្តោប្រវេសន៍របស់ខ្លួនដើម្បីក្លាយជា LPR
- ជា LPR និងកំពុងវិលត្រឡប់ចូលប្រទេសវិញបន្ទាប់ពីចាកចេញពីសហរដ្ឋអាមេរិកអស់រយៈពេលលើសពី 6 ខែជាប់ៗគ្នា។

3. **តើវិធានស្តីពីជនក្រោមបន្ទុកសាធារណៈមានការផ្លាស់ប្តូរដែរឬទេ?**
នៅឆ្នាំ2019 ក្រោមការដឹកនាំរបស់រដ្ឋបាលលោក Trump រដ្ឋាភិបាលសហព័ន្ធបានពង្រីកបញ្ជីកម្មវិធីដែលអាចនឹងត្រូវពិចារណាក្រោមការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈ។ ប៉ុន្តែនៅឆ្នាំ2021 ក្រសួងសន្តិសុខមាតុភូមិ (DHS) **បានលុបចោល**វិធានស្តីពីជនក្រោមបន្ទុកសាធារណៈ ដែលបានដាក់ឱ្យអនុវត្តនៅឆ្នាំ2019។

**សម្គាល់៖** គិតត្រឹមខែសីហា ឆ្នាំ2021 រដ្ឋបាលលោក Biden កំពុងពិនិត្យមើលបច្ចុប្បន្នភាពនៃវិធានស្តីពីជនក្រោមបន្ទុកសាធារណៈ ដែលនឹងកាត់បន្ថយភាពភ័យខ្លាចរបស់ជនអន្តោប្រវេសន៍ក្នុងការទទួល

បានអត្ថប្រយោជន៍សាធារណៈនាពេលអនាគត។
ការិយាល័យគោលនយោបាយនឹងធ្វើការតាមដានយ៉ាងជិតដល់ និងផ្តល់ជូននូវព័ត៌មានបច្ចុប្បន្នភាពតាមការសមស្រប។

4. **តើចំណុចនេះមានន័យយ៉ាងដូចម្តេចចំពោះជនអន្តោប្រវេសន៍?**
- ជនអន្តោប្រវេសន៍អាចប្រើប្រាស់ដោយសុវត្ថិភាពនូវកម្មវិធីសុខភាព អាហារូបត្ថម្ភ និងលំនៅដ្ឋានដែលខ្លួន និងក្រុមគ្រួសារមានសិទ្ធិទទួលបាន។
- ការប្រើប្រាស់របស់ជនអន្តោប្រវេសន៍នូវកម្មវិធី Medi-Cal, CalFresh, លំនៅដ្ឋានសាធារណៈ ឬផ្នែកទី 8 សក្ខីបត្រជំនួយថ្លៃឈ្នួល នឹង**លែងលើកមកពិចារណាទៀតហើយ** នៅពេលដាក់ពាក្យសុំស្ថានភាព LPR ឬចូលទឹកដីសហរដ្ឋអាមេរិក។
- ការព្យាបាលវេជ្ជសាស្ត្ររបស់ជនអន្តោប្រវេសន៍ ឬសេវាការពារជំងឺ COVID -19 រួមទាំងវ៉ាក់សាំង នឹង**មិន**ត្រូវបានពិចារណាសម្រាប់គោលបំណងវិធានស្តីពីជនក្រោមបន្ទុកសាធារណៈឡើយ។

5. **តើកម្មវិធីណាខ្លះដែលនឹងត្រូវបន្តពិចារណាក្នុងការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈ**?
ប្រសិនបើអ្នកដាក់ពាក្យសុំ LPR ឬចូលក្នុងប្រទេស

**មានតែកម្មវិធីមួយចំនួនប៉ុណ្ណោះ**ដែលត្រូវបានពិចារណាក្រោមការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈ មានដូចខាងក្រោម៖

- កម្មវិធីជំនួយសាច់ប្រាក់ដូចជា CalWORKs ជំនួយទូទៅ (GA) និងប្រាក់ចំណូលសន្តិសុខបន្ថែម (SSI)
- ការថែទាំរយៈពេលវែងក្នុងមណ្ឌល ដែលត្រូវបានទូទាត់ជូនដោយ Medi-Cal

ការប្រើប្រាស់អត្ថប្រយោជន៍ទាំងនេះតែមួយគត់ នឹងមិនទទួលបានការកំណត់ជាស្វ័យប្រវត្តិថា អ្នកអាចនឹងក្លាយជាជនក្រោមបន្ទុកសាធារណៈឡើយ ដោយវាគ្រាន់តែជាកត្តាមួយនៅក្នុងចំណោមកត្តាផ្សេងៗមួយចំនួនដែលត្រូវបានពិចារណា នៅពេលធ្វើការសម្រេចចិត្តតែប៉ុណ្ណោះ។

6. **ខ្ញុំបានទទួលព័ត៌មានថា ប្រសិនបើខ្ញុំទទួលបានកម្មវិធី CalFresh អាចនឹងកាន់តែលំបាកសម្រាប់ខ្ញុំក្នុងការទទួលបាន LPR របស់ខ្ញុំ។ តើនេះជាការពិតដែរឬទេ?**
មិនដូច្នោះទេ អត្ថប្រយោជន៍ CalFresh មិនត្រូវបានពិចារណានៅក្នុងការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈឡើយ។

7. **ខ្ញុំបានទទួលព័ត៌មានថាប្រសិនបើខ្ញុំទទួលបានកម្មវិធី Medi-Cal អាចនឹងកាន់តែលំបាកសម្រាប់ខ្ញុំក្នុងការទទួលបាន LPR របស់ខ្ញុំ។ តើនេះជាការពិតដែរឬទេ?**
មិនដូច្នោះទេ អត្ថប្រយោជន៍ Medi-Cal មិនត្រូវបានពិចារណានៅក្នុងការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈឡើយ។

8. **ខ្ញុំបានទទួលព័ត៌មានថា ប្រសិនបើខ្ញុំរស់នៅក្នុងលំនៅដ្ឋានសាធារណៈ ឬទទួលបានសក្ខីបត្រលំនៅដ្ឋាន ឬជំនួយថ្លៃឈ្នួលផ្សេងទៀត អាចនឹងកាន់តែលំបាកសម្រាប់ខ្ញុំក្នុងការទទួលបាន LPR របស់ខ្ញុំ។ តើនេះជាការពិតដែរឬទេ?**
មិនដូច្នោះទេ ការរស់នៅក្នុងលំនៅដ្ឋានសាធារណៈ ការទទួលបានសក្ខីបត្រលំនៅដ្ឋាន ឬជំនួយថ្លៃឈ្នួលផ្សេងទៀតមិនត្រូវបានពិចារណានៅក្នុងការធ្វើតេស្តជនក្រោមបន្ទុកសាធារណៈឡើយ។

9. **តើដូចម្តេចដែរ ប្រសិនបើខ្ញុំមិនទទួលបានអត្ថប្រយោជន៍ណាមួយ ប៉ុន្តែកូនៗរបស់ខ្ញុំទទួលបាន។ តើការប្រើប្រាស់អត្ថប្រយោជន៍របស់ពួកគេនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំ LPR របស់ខ្ញុំដែរឬទេ**?
អត់ទេ អត្ថប្រយោជន៍ដែលទទួលបានក្នុងនាមកុមារនឹងមិនប៉ះពាល់ដល់ការដាក់ពាក្យស្នើសុំ LPR របស់បុគ្គលណាម្នាក់ឡើយ។

10. **តើវិធានស្តីពីជនក្រោមបន្ទុកសាធារណៈចុងក្រោយអនុវត្តចំពោះជនអន្តោប្រវេសន៍ទាំងអស់ឬ**?
មិនដូច្នោះទេ ខាងក្រោមនេះគឺជាបញ្ជីប្រភេទដែលត្រូវបាន<u>លើកលែង</u>៖

- ពលរដ្ឋអាមេរិកចូលសញ្ជាតិ
- ពលរដ្ឋអចិន្ត្រៃយ៍ស្របច្បាប់
- ជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធជ្រកកោន
- ស្ថានភាពជាអនីតិជនអន្តោប្រវេសន៍ពិសេស
- អ្នកកាន់ទិដ្ឋាការ U-Visa និង T-Visa
- អ្នកដាក់ពាក្យស្នើសុំខ្លួនឯងនៃច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី (VAWA)
- ជនចំណូលថ្មីក្នុងស្ថានភាពជាកុមារវិធានការត្រូវពន្យារ (DACA)
- ស្ថានភាពការពារបណ្តោះអាសន្ន (TPS)
- ជនអន្តោប្រវេសន៍ពិសេសអាហ្វហ្គានីស្ថាននិងអ៊ីរ៉ាក់
- បុគ្គលដែលទទួលបានជំនួយសង្គ្រោះនៅក្រោម៖
    - CAA
    - NACARA
    - HRIFA

ករណីអន្តោប្រវេសន៍នីមួយៗមានលក្ខណៈពិសេសផ្សេងគ្នា។ ទីភ្នាក់ងារសេវាសង្គម (SSA) បន្តលើកទឹកចិត្តដល់អ្នកទទួលសេវា និងសាធារណៈជនឱ្យទាក់ទងមកបណ្តាញផ្តល់ជំនួយផ្នែកច្បាប់តំបន់ឈូងសមុទ្រ (Bay Area Legal Aid FREE Legal Advice Line) ឥតគិតថ្លៃ តាមរយៈលេខ 1 (800) 551-5554

ប្រសិនបើខ្លួនមានសំណួរអំពីថាតើការប្រើប្រាស់អត្ថប្រយោជន៍សាធារណៈអាចប៉ះពាល់ដូចម្តេចខ្លះដល់ស្ថានភាពអន្តោប្រវេសន៍របស់ពួកគេ។ ការផ្តល់ជំនួយនេះមានជាគ្រប់ភាសាទាំងអស់។

**11. តើតេស្តជនក្រោមបន្ទុកសាធារណៈត្រូវបានប្រើប្រាស់ដែរឬទេ ប្រសិនបើបុគ្គលម្នាក់ដាក់ពាក្យស្នើសុំចូលសញ្ជាតិ (សញ្ជាតិ)?**
អត់ទេ វិធានស្តីពីជនក្រោមបន្ទុកសាធារណៈមិនអនុវត្តចំពោះការស្នើសុំចូលសញ្ជាតិ (សញ្ជាតិ) ទេ។

**12. ខ្ញុំមានសំណួរអំពីស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ និងថាតើខ្ញុំត្រូវដាក់ពាក្យសុំអត្ថប្រយោជន៍សាធារណៈដែរឬទេ។ តើខ្ញុំគួរទាក់ទងទៅនរណាដើម្បីសាកសួរអំពីករណីរបស់ខ្ញុំនេះ?**
ទីភ្នាក់ងារសេវាសង្គមសូមលើកទឹកចិត្តដល់បុគ្គល និងក្រុមគ្រួសារឱ្យធ្វើការស្វែងរកការប្រឹក្សាយោបល់ពីអ្នកផ្តល់សេវាអន្តោប្រវេសន៍ល្បីឈ្មោះមិនរកប្រាក់ចំណេញ រួមមានដូចជា ការបញ្ជូនបន្តដូចខាងក្រោម៖

- ទំនាក់ទំនងផ្នែកច្បាប់ Asian Pacific Islander (510) 251-2846
- ជំនួយផ្នែកច្បាប់តំបន់ឆ្នេរសមុទ្រ (Bay Area Legal Aid) 1 (800) 551-5554 ឬ (510) 250-5270
- អង្គការសប្បុរសកាតូលិកនៃឈូងសមុទ្រខាងកើត (Catholic Charities of the East Bay) (510) 768-3100
- Centro Legal De La Raza (510) 437-1554
- មជ្ឈមណ្ឌលច្បាប់សហគមន៍ឈូងសមុទ្រខាងកើត (East Bay Community Law Center) (510) 548-4040
- វិទ្យាស្ថានអន្តរជាតិនៃឈូងសមុទ្រខាងកើត (International Institute of the East Bay) (510) 451-2846 x 301

**13. តើសិទ្ធិទទួលបានអត្ថប្រយោជន៍សាធារណៈមានការផ្លាស់ប្តូរដែរឬទេ?**
អត់ទេ ច្បាប់សម្រាប់អត្ថប្រយោជន៍ និងសេវាសាធារណៈរបស់រដ្ឋ California មិនមានការផ្លាស់ប្តូរទេ។ លក្ខខណ្ឌសិទ្ធិទទួលបាននៅតែដដែលសម្រាប់បុគ្គល និងគ្រួសារ។ ទីភ្នាក់ងារសេវាសង្គមនឹងបន្តដំណើរការរាល់ការដាក់ពាក្យសុំ និងការបន្តទាំងអស់ ព្រមទាំងផ្តល់អត្ថប្រយោជន៍ដល់បុគ្គល និងគ្រួសារដែលមានសិទ្ធិ ដូចពួកគេបានអនុវត្តនៅមុនពេលមានវិធានស្តីពីជនក្រោមបន្ទុកសាធារណៈថ្មី។

**14. តើចំណុចនេះមានន័យដូចម្តេចចំពោះបុគ្គល និងគ្រួសារដែលបច្ចុប្បន្នកំពុងទទួលបានអត្ថប្រយោជន៍សាធារណៈ និងមានករណីអន្តោប្រវេសន៍មិនទាន់បញ្ចប់? តើពួកគេគួរធ្វើដូចម្តេច?**
ករណីអន្តោប្រវេសន៍នីមួយៗមានកាលៈទេសៈពិសេសផ្សេងពីគ្នា ដោយគ្មានករណីចំនួនពីរណាមួយដូចគ្នាឡើយ។ បុគ្គល និងក្រុមគ្រួសារគួរទទួលបានការណែនាំឱ្យពិភាក្សាជាមួយមេធាវីអន្តោប្រវេសន៍ល្បីឈ្មោះ។ **ទោះក្នុងករណីណាក៏ដោយ បុគ្គលិកភ្នាក់ងារសេវាសង្គមមិនគួរផ្តល់ការណែនាំផ្លូវច្បាប់ដល់បុគ្គលនិងគ្រួសារឡើយ។**

**15. បុគ្គល និងគ្រួសារមានការព្រួយបារម្ភអំពីឯកជនភាពនៃព័ត៌មានរបស់ខ្លួន។ តើព័ត៌មានដែលពួកគេផ្តល់ឱ្យ នឹងត្រូវប្រើប្រាស់ភ្នាក់ងារសេវាសង្គមយ៉ាងដូចម្តេច?**
ទីភ្នាក់ងារសេវាសង្គមប្រើប្រាស់ព័ត៌មានដែលបានផ្តល់ជូនដើម្បីពិនិត្យមើលថាតើបុគ្គល និងគ្រួសារមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដែរឬទេ។ រដ្ឋាភិបាលសហព័ន្ធពុំមានសិទ្ធិចូលទៅក្នុងប្រព័ន្ធរបស់ទីភ្នាក់ងារដើម្បីអនុវត្តច្បាប់អន្តោប្រវេសន៍ឡើយ។ ទីភ្នាក់ងារសេវាសង្គមប្រហែលជាត្រូវធ្វើការផ្ទៀងផ្ទាត់ព័ត៌មានដែលបានផ្តល់ជូននៅលើពាក្យសុំអត្ថប្រយោជន៍សាធារណៈជាមួយរដ្ឋាភិបាលសហព័ន្ធ ប៉ុន្តែគ្រាន់តែដើម្បីបញ្ជាក់អំពីសិទ្ធិទទួលបានសេវាកម្មប៉ុណ្ណោះ។ ទីភ្នាក់ងារមិនចែករំលែកព័ត៌មានណាមួយអំពីសមាជិកគ្រួសារដែលមិនបានដាក់ពាក្យសុំអត្ថប្រយោជន៍ឡើយ គឺគ្រាន់តែព័ត៌មានដែលបានផ្តល់ជូនអំពីអ្នកឧបត្ថម្ភហិរញ្ញវត្ថុប៉ុណ្ណោះ។

**16. តើការបញ្ឈប់អត្ថប្រយោជន៍នឹងដកព័ត៌មានករណីចេញពីប្រព័ន្ធកុំព្យូទ័ររបស់នាយកដ្ឋានសេវាសង្គម CA ដែរឬទេ?**
អត់ទេ ប្រព័ន្ធកុំព្យូទ័ររបស់រដ្ឋ និងថ្នាក់មូលដ្ឋានរក្សាទុកនូវកំណត់ត្រានៃករណីទាំងអស់ ដូច្នេះភ្នាក់ងារសេវាសង្គមនឹងបន្តមានព័ត៌មាននៅក្នុងសំណុំឯកសារដដែល។

**17. តើបុគ្គលអាចស្វែងរកព័ត៌មានបន្ថែមអំពីជនក្រោមបន្ទុកសាធារណៈពីកន្លែងណាខ្លះ?**
- នាយកនាយកដ្ឋានសេវាសង្គម California (California Department of Social Services)
- សមាគមនាយកសុខមាលភាពខោនធីនៃរដ្ឋ California (County Welfare Directors Association of California)
- មជ្ឈមណ្ឌលច្បាប់អន្តោប្រវេសន៍ជាតិ (National Immigration Law Center)
- មជ្ឈមណ្ឌលគោលនយោបាយជនអន្តោប្រវេសន៍ CA (CA Immigrant Policy Center)

**18. តើព័ត៌មានស្តីពីវិធានជនក្រោមបន្ទុកសាធារណៈអាចបន្តចែករំលែកដែរឬទេ?**
អាចចែករំលែកបាន។ សម្រាប់ព័ត៌មានអំពីអន្តោប្រវេសន៍ថ្មីៗ សូមចូលមើលគេហទំព័រទំនាក់ទំនងជនអន្តោប្រវេសន៍របស់ទីភ្នាក់ងារ។ សម្រាប់ព័ត៌មានបន្ថែម សូមមើល សេចក្តីប្រកាសសេវាសាធារណៈស្តីពីជនក្រោមបន្ទុកសាធារណៈ។